កិច្ចការ២៣:១-៣៥

# ជំពូក ២៣

***ខាងចនា*** *សាវ័កប៉ុលធ្វើទីបន្ទាល់នៅមុខគណៈសង្ឃ*

*ព្រះអម្ចាស់បើកសម្តែងអោយសាវ័កប៉ុលឃើញ*

*ផែនការសម្ងាត់ក្នុងការសម្លាប់សាវ័កប៉ុល*

*គេបញ្ជូនសាវ័កប៉ុលទៅក្រុងសេសារា*

នៅក្នុងពេលនេះ សាវ័កប៉ុលបានក្លាយត្រឡប់ទៅជាអ្នកជាប់ឃុំហើយ។ ចាប់ពីគ្រានេះទៅ សាវ័កប៉ុលត្រូវធ្វើទីបន្ទាល់ពីព្រះអម្ចាស់យេស៊ូវ នៅមុខអ្នកមានបណ្តាស័ក្តិ និងអ្នកកាន់អំណាចនានា។ ពួកសាសន៍យូដានាំគ្នាធ្វើឧបាយកល ដើម្បីសម្លាប់លោក ប៉ុន្តែរាជការរ៉ូមបានដឹងរឿងនោះទាន់ ក៏បញ្ជូនលោកទៅដាក់ក្នុងមន្ទីរឃុំឃាំងក្រុងសេសារា។ បន្ទាប់ពីចំណាយពេលពីរឆ្នាំ នៅទីនោះមក លោកសូមរើក្តីទៅក្រុងរ៉ូមវិញ។

អ្នកបកស្រាយគម្ពីរខ្លះបន្ទោសថា បើកុំតែសាវ័កប៉ុលចចេសចុះទៅទីក្រុងយេរូសាឡិម ម្ល៉េះគាត់មិនត្រូវមានទុក្ខលំបាកបែបនេះទេ។ ប៉ុន្តែ ដំណើរនេះសាវ័កប៉ុលចុះទៅទីក្រុងយេរូសាឡិម តាមបំណងព្រះហឫទ័យរបស់ព្រះទេ។ ជាការពិតហើយ ការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអាចនាំមកនូវគ្រោះថ្នាក់ដល់ជីវិតក៏

សឹងមាន។ សូមអោយយើងយល់ថា ការឆ្លងកាត់ទុក្ខលំបាក ពិតជាស្ថិតនៅក្នុងបំណងព្រះហឫទ័យរបស់ព្រះចំពោះជីវិតយើង។

ព្រះហស្ដរបស់ព្រះជាម្ចាស់កំពុងសណ្ឋិតនៅលើជីវិតរបស់សាវ័កប៉ុល។ អង្គដែលគ្រប់គ្រងជីវិតរបស់សាវ័កប៉ុល គឺជាព្រះដដែល ដែលកំពុងគ្រប់គ្រងជីវិតរបស់លោកអ្នកក្នុងពេលសព្វថ្ងៃនេះ។ ព្រះជាម្ចាស់ទទួលសិរីល្អតាមរយៈទុក្ខលំបាករបស់កូនទ្រង់។ សព្វថ្ងៃយើងដើរនៅក្នុងជីវិតដែលជួបប្រទះម្ដងសុខម្ដងទុក្ខ តែត្រូវដឹងថាព្រះជាម្ចាស់គង់នៅក្នុងជីវិតរបស់យើង។ ការរស់នៅប្រចាំថ្ងៃតែងមានការលំបាកនេះជាធម្មតា។ ប៉ុន្តែ ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ជាមួយនឹងជីវិតរបស់យើង ទោះបីយើងមានការលំបាកយ៉ាងដូច្នោះក៏ដោយ។ យើងពិតជាត្រូវការជំនួយពីព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងជាប្រាកដ។ យើងមិនត្រូវអួតអាងថា យើងមិនចាំបាច់ត្រូវការព្រះជាម្ចាស់នៅក្នុងពេលសព្វថ្ងៃនេះទេ។

ម្យ៉ាងវិញទៀត ខ្ញុំចង់អោយលោកអ្នកបងប្អូនជ្រាបថា សព្វថ្ងៃនេះមានមនុស្សចង់យកតម្រាប់តាមជីវិតរបស់សាវ័កប៉ុល។ ខ្ញុំយល់ថា យើងមិនចាំបាច់ធ្វើអោយមានមនោសញ្ចេតនាដូចសាវ័កប៉ុលនោះទេ។ ជីវិតរបស់យើងសព្វថ្ងៃនេះ យើងមានបទពិសោធន៍មួយយ៉ាងធំក្នុងការដើរជាមួយព្រះ។ យើងគ្រាន់តែជឿដល់ព្រះយេស៊ូវថាទ្រង់ពិតជាដឹកនាំយើងអោយដើរក្នុងមួយថ្ងៃៗនោះគ្រប់គ្រាន់ហើយ។

ពួកគណៈសង្ឃគឺជាគណៈកម្មការតុលាការសាសនា ដែលមានរួមទាំងពួកសាឌូសី និងពួកផារីស៊ីផង។ នៅមុខគណៈសង្ឃសាវ័កប៉ុលមិនអាចពន្យល់រឿងក្ដីរបស់

លោកអោយគេយល់បានទេ។ ព្រះជាម្ចាស់យាងមកលើកទឹកចិត្តដល់សាវ័កប៉ុល។ ក្រោយមកពួកយូដានាំគ្នាធ្វើឧបាយកលសម្លាប់សាវ័កប៉ុលដោយសម្ងាត់។ ប៉ុន្តែ ពួករាជការរ៉ូមដឹងរឿងនោះទាន់ គេក៏រំដោះលោកយកទៅប្រគល់អោយលោកភីលេចវិញ។ រឿងដែលកើតឡើងក្នុងជំពូក២៣ ធ្វើអោយយើងមានការតក់ស្លុតផង មានការរីករាយផង។ ដ្បិតយើងឃើញសាវ័កប៉ុល ដែលជាអ្នកជាប់គុកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវ លោករងទុក្ខផង លោកទទួលការការពារយ៉ាងល្អផង។

## សាវ័កប៉ុលធ្វើទីបន្ទាល់នៅមុខគណៈសង្ឃ

**[1]ប៉ុលក៏សំឡឹងមើលទៅពួកក្រុមជំនុំ និយាយថា ឱអ្នករាល់គ្នា ជាបងប្អូនអើយ ខ្ញុំបានប្រព្រឹត្តដោយបញ្ញាចិត្តជ្រះស្អាតនៅចំពោះព្រះដរាបមកដល់ថ្ងៃនេះ [2]តែអាន់នាសជាសំដេចសង្ឃ លោកបង្គាប់ដល់ពួកអ្នកដែលឈរជិត ឲ្យទះមាត់គាត់ (កិច្ចការ២៣: ១-២)។**

នៅពេលនេះ គេនាំសាវ័កប៉ុលមកធ្វើទីបន្ទាល់នៅមុខគណៈសង្ឃ។ ប្រធានគណៈសង្ឃជាមនុស្សកាចសាហាវខ្លាំងណាស់។ លោកបង្គាប់អោយគេទះមាត់សាវ័កប៉ុលទាំងកម្រោល។

**នោះប៉ុលនិយាយទៅលោកថា ឱកំផែងលាបសអើយ ព្រះទ្រង់នឹងវាយលោកវិញ លោកអង្គុយជំនុំជំរះខ្ញុំតាមក្រឹត្យវិន័យ ចុះដូចម្តេចបានជាហ៊ានបង្គាប់ឱ្យគេវាយខ្ញុំ ខុសនឹងក្រឹត្យវិន័យដូច្នេះ (កិច្ចការ ២៣:៣)។**

ច្បាប់តុលាការរាជការរ៉ូមមិនអនុញ្ញាតអោយជនណាវាយអ្នកចុងចោទ មុននឹងតុលាការរកឃើញថា អ្នកនោះពិតជាមានទោសកំហុសដូចគេចោទប្រកាន់មែន។ នៅក្នុងសម័យដើមច្បាប់រាជការរ៉ូម ការពារយុត្តិធម៌គួរសមដែរ។ ប៉ុន្តែ នៅពេលដែលគេកាត់ទោសព្រះអម្ចាស់យេស៊ូវ ច្បាប់យុត្តិធម៌របស់រាជការរ៉ូម ត្រូវគេយកមកមូលកាច់ទៅតាមមតិភាគច្រើន។ ដូច្នេះ អំពើយុត្តិធម៌គ្រាន់តែជាការកំណត់របស់អ្នកកាន់អំណាចតែប៉ុណ្ណោះ។

តើត្រូវធ្វើដូចម្តេច ដើម្បីអោយមានអំពើយុត្តិធម៌ពិតប្រាកដនៅក្នុងសង្គម? អ្នកខ្លះយល់ថា បើយើងដូររដ្ឋាភិបាលដែលកាន់អំណាចនៅក្នុងនគរសព្វថ្ងៃ ស្ថានភាពនឹងពិតជាមានការប្តូរផ្លាស់ប្រសើរឡើងជាមិនខាន។ លោកអ្នកបងប្អូនអើយ សូមកុំអោយមានការស្រមើស្រមៃយ៉ាងដូច្នោះឡើយ។ រដ្ឋាភិបាលដែលឡើងកាន់អំណាចទោះជារដ្ឋាភិបាលណាក៏ដោយ សុទ្ធតែជាមនុស្សមានបាបដូចពលរដ្ឋឯទៀតៗដែរ។ ធម្មតាមនុស្សមានបាបមិនចេះកោតខ្លាចដល់ព្រះជាម្ចាស់ទេ។ ការប្តូរផ្លាស់រដ្ឋាភិបាលដែលកំពុងគ្រប់គ្រងនគរ មិនមែនជាចម្លើយសម្រាប់ដោះស្រាយបញ្ហាអយុត្តិធម៌ឡើយ។

អ្នកដឹកនាំនគរត្រូវប្តូរចិត្តរបស់លោក ពោលគឺពីចិត្តដែលមិនទាន់ស្គាល់ព្រះជាម្ចាស់ មកស្តាប់បង្គាប់ដល់ព្រះបន្ទូលរបស់ព្រះអង្គ នោះទើបនគរនីមួយៗមានការប្រសើរឡើង។ យើងមិនចាំបាច់ប្តូរប្រព័ន្ធដឹកនាំទេ យើងត្រូវដូរចិត្តគំនិតវិញ។ ឯការដូរចិត្តគំនិតទៀតសោត គឺត្រូវដូរពីសណ្ឋានមានបាប អោយមកជាសណ្ឋានមនុស្សដែលព្រះជាម្ចាស់រាប់ថា ជាអ្នកសុចរិតក្នុងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ប្រធានគណៈសង្ឃបង្គាប់អោយគេទះមាត់សាវ័កប៉ុល។ សាវ័កប៉ុលបាននិយាយបន្ទោសដល់សម្តេចសង្ឃនៅមុខទីសាធារណៈ។ ត្រង់នេះបញ្ជាក់អោយឃើញថា សាវ័កប៉ុលមិនមែនជាមនុស្សដែលគេជិះជាន់ស្រេចនឹងចិត្តនោះទេ។ មនុស្សខ្លះកាលណាឃើញអ្នកចេះដឹងបន្ទាបខ្លួន គេច្រើនតែយកជើងជាន់ក្បាលបន្ថែម។ សាវ័កប៉ុលជាមនុស្សបន្ទាបខ្លួន ពីព្រោះលោកស្ម័គ្រចិត្តចុះចូលចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទោះបីគេមើលងាយ មើលថោកលោកយ៉ាងណាក៏ដោយ។ ប៉ុន្តែលុះដល់គេចោទប្រកាន់លោកដោយអយុត្តិធម៌ លោកមិនអនុញ្ញាតអោយគេជិះសេះលែងដៃដាក់លោករបៀបនោះទេ។ សាវ័កប៉ុលហៅសម្តេចសង្ឃថា "...ឱកំផែងលាបសអើយ ព្រះទ្រង់នឹងវាយលោកវិញ លោកអង្គុយជំនុំជំរះខ្ញុំតាមក្រិត្យវិន័យ ចុះដូចម្តេចបានជាហ៊ានបង្គាប់ឱ្យគេវាយខ្ញុំ ខុសនឹងក្រិត្យវិន័យដូច្នេះ"។ សាវ័កប៉ុលចេះច្បាប់ទម្លាប់យ៉ាងស្ទាត់ជំនាញ។ លោកមិនគួរអោយគេវាយលោក មុននឹងគេរកឃើញថាលោកខុសច្បាប់អ្វីមួយតាមច្បាប់តុលាការទេ។

**ឯពួកអ្នកដែលឈរជិតក៏ស្តីឱ្យគាត់ថា តើឯងហ៊ានជេរដល់សំដេចសង្ឃនៃព្រះដែរឬ (កិច្ចការ២៣:៤)។**

សាវ័កប៉ុលមិនស្គាល់ថា មនុស្សដែលបង្គាប់អោយគេទះមាត់លោកជាសម្តេចសង្ឃឡើយ។ ភ្នែកលោកមើលមិនច្បាស់ បានជាលោកមានប្រសាសន៍យ៉ាងដូច្នោះ។ នៅពេលដែលលោកសរសេរសំបុត្រទៅកាន់ពួកជំនុំផ្សេងៗ យើងឃើញមានសេចក្តីមួយទៀត ដែលលោកបញ្ជាក់ថា ភ្នែកលោកមើលមិនច្បាស់ទេ។

**ប៉ុលឆ្លើយថា បងប្អូនអើយ ខ្ញុំមិនបានដឹងថា លោកជាសំដេចសង្ឃទេ ដ្បិតមានសេចក្តីចែងទុកមកថា "មិនត្រូវនិយាយអាក្រក់ពីចៅហ្វាយរបស់សាសន៍ឯងឡើយ" (កិច្ចការ២៣:៥)។**

សាវ័កប៉ុលចេះច្បាប់ទម្លាប់ ព្រមទាំងជាអ្នកអនុវត្តច្បាប់ផង។ ក្រឹត្យវិន័យមិនអនុញ្ញាតអោយអ្នកតូចមើលងាយអ្នកធំ។

សព្វថ្ងៃការគោរពដល់អ្នកកំពូល ក្លាយត្រឡប់ទៅជាការលេងសើចទៅហើយ។ កាសែតខ្លះ បើកមាត់ឡើងជេរប្រទេចដល់អ្នកកំពូល ដែលមានអំណាចកាន់កាប់នគរទាំងមូល។ យើងមិនគួរជៀលត្មិះជេរប្រទេចដល់អ្នកដឹកនាំរបស់យើងទេ ពីព្រោះលោកមាននាទីខ្ពង់ខ្ពស់ក្នុងការដឹកនាំជាតិទាំងមូល។ យើងជាមនុស្សលោកចាំ

បាច់ត្រូវចុះចូលជាមួយនឹងច្បាប់របស់នគរ។ សាវ័កប៉ុលសរសេរនៅក្នុងគម្ពីររ៉ូមថា "ដូច្នេះ ចូរសងដល់លោកទាំងនោះ តាមដែលអ្នកជំពាក់ចុះ គឺឱ្យបង់ពន្ធខ្លួនដល់លោកណាដែលត្រូវទទួលបង់ពន្ធគយ ដល់លោកណាដែលទទួលខាងពន្ធគយ ត្រូវមានសេចក្តីកោតខ្លាច ចំពោះលោកណាដែលគួរកោតខ្លាច ហើយត្រូវគោរពប្រតិបត្តិដល់លោកណាដែលគួរគោរពដែរ" (រ៉ូម១៣:៧)។ សាវ័កប៉ុលសរសេរសេចក្តីនេះ នៅពេលដែលលោកជាប់ព័ន្ធនាគារក្រោមការគ្រប់គ្រងរាជ្យរបស់ស្តេចនេរ៉ូ ជាស្តេចកាចសាហាវជាទីបំផុត។

> **កាលប៉ុលបានដឹងថា ពួកគេ១ចំណែកជាពួកសាឌូស៊ី ហើយ១ចំណែកទៀតជាពួកផារិស៊ី នោះគាត់បន្លឺសំឡេងឡើងក្នុងពួកក្រុមជំនុំថា បងប្អូនរាល់គ្នាអើយ ខ្ញុំជាពួកផារិស៊ី ហើយជាកូននៃពួកផារិស៊ី ខ្ញុំជាប់ជំនុំជំរះ គឺដោយព្រោះតែសេចក្តីសង្ឃឹមនេះថា មនុស្សស្លាប់នឹងរស់ឡើងវិញ (កិច្ចការ២៣:៦)។**

បទគម្ពីរខាងលើ បង្ហើបអោយយើងដឹងខ្លះៗអំពីជីវប្រវត្តិរបស់សាវ័កប៉ុល។ ឪពុករបស់លោកជាអ្នកមាន និងមានឥទ្ធិពលក្នុងចំណោមពួកផារីស៊ី។ ,

ពេលនេះសាវ័កប៉ុលជ្រាបថា នៅក្នុងចំណោមគណៈសង្ឃមាននិកាយពីរដែលមិនសូវត្រូវគ្នាទេ។ ពួកផារីស៊ីជឿ និងមានសេចក្តីសង្ឃឹមនៅលើការរស់ឡើងវិញ។ ពួកសាឌូស៊ីមិនជឿយ៉ាងដូច្នោះឡើយ។ សាវ័កប៉ុលបានបំផ្លាស់រឿងក្តីអោយទៅជារឿង

គោលទ្ធិវិញ។ រឿងគោលទ្ធិធ្វើអោយមនុស្សភ្លេចមិត្តភក្តិក៏សឹងមាន។

> **៧ កាលគាត់និយាយដូច្នោះហើយ នោះពួកផារិសី នឹងពួកសាឌូសី**
> **គេកើតទាស់ទែងគ្នា បណ្តាជំនុំក៏បែកខ្ញែកដែរ ៨ ដ្បិតពួកសាឌូសី**
> **ប្រកាន់ថា គ្មានសេចក្តីរស់ឡើងវិញ ក៏គ្មានទេវតា ឬវិញ្ញាណណា**
> **ផង តែពួកផារិសីជឿថា មានវិញ ៩ នោះកើតមានសូរទ្រហឹងអឹង**
> **អាប់ជាខ្លាំង ហើយពួកអាចារ្យខ្លះខាងពួកផារិសី ក៏ឈរឡើង**
> **ជជែកថា យើងមិនឃើញជាមនុស្សនេះមានទោសខុសអ្វីសោះ**
> **តែបើមានវិញ្ញាណ ឬទេវតាបាននិយាយនឹងគាត់ នោះធ្វើដូចម្តេច**
> **វិញ (កិច្ចការ២៣:៧-៩)។**

លុះពួកផារីស៊ីដឹងថា សាវ៉កប៉ុលជាពួកផារីស៊ីដូចខ្លួនដែរ គេក៏នាំគ្នាការពារ រឿងក្តីរបស់លោក។

> **លុះកើតទាស់គ្នាជាខ្លាំងដូច្នោះ នោះមេទ័ពធំក៏បង្គាប់ឱ្យពួកទាហានចុះទៅ យកគាត់ពីកណ្តាលគេមក ដោយអំណាច ហើយនាំចូលទៅក្នុងបន្ទាយវិញ ក្រែងលោគេប្រញាយហែកគាត់ខ្ទេចខ្ទីទៅ (កិច្ចការ២៣:១០)។**

បណ្ឌិតលូកាបញ្ជាក់ថា មានការទាស់ទែងគ្នាជាខ្លាំង បណ្ដាលអោយជីវិតរបស់សាវ័កប៉ុល អាចមានគ្រោះថ្នាក់ដល់ស្លាប់។ បើកុំតែមេទ័ពរាជការមកជួយរំដោះចេញពីកំហឹងរបស់គណៈសង្ឃ សាវ័កប៉ុលប្រហែលជាត្រូវស្លាប់នៅក្នុងពេលនេះបាត់ទៅហើយ។ នៅក្នុងករណីដែលមេទ័ពរាជការរ៉ូមដណ្ដើមសាវ័កប៉ុលចេញពីពួកអ្នកកាន់សាសនា យើងសន្និដ្ឋានថា ច្បាប់របស់រាជការរ៉ូមចែកដាច់ច្បាប់សាសនា និងច្បាប់រដ្ឋ។ កិរិយារបស់លោកកាលីយ៉ូ ក៏សបញ្ជាក់ថា ច្បាប់រដ្ឋនិងច្បាប់សាសនាត្រូវតែគិតគូរដាច់ពីគ្នា។

## ព្រះជាម្ចាស់បើកសម្ដែងអោយសាវ័កប៉ុលឃើញ

**នៅវេលាយប់នោះ ព្រះអម្ចាស់ទ្រង់ឈរជិតគាត់មានបន្ទូលថា ចូរសង្ឃឹមឡើង ប៉ុលអើយ ដ្បិតអ្នកត្រូវធ្វើបន្ទាល់នៅក្រុងរ៉ូម ដូចជាបានធ្វើបន្ទាល់សព្វគ្រប់ពីខ្ញុំនៅក្រុងយេរូសាឡិមដែរ (កិច្ចការ ២៣:១១)។**

សេចក្ដីដែលសម្ដែងនៅក្នុងខាងលើ បញ្ជាក់ម្ដងទៀតថា សាវ័កប៉ុលចុះទៅទីក្រុងយេរូសាឡិមតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ព្រះវិញ្ញាណរបស់ព្រះជាស់តឿនដល់សាវ័កប៉ុលថា បើលោកចុះទៅទីក្រុងយេរូសាឡិម លោកពិតជាជួបជាមួយនឹងគ្រោះថ្នាក់ជាពិតប្រាកដ។ ប៉ុន្ដែ សាវ័កប៉ុលត្រៀមខ្លួន ដើម្បីចុះចូលជាមួយនឹង

បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ វត្ថុបំណងរបស់លោក គឺចង់ធ្វើបន្ទាល់ពីព្រះអម្ចាស់យេស៊ូវដល់អ្នកដឹកនាំនៅក្នុងទីក្រុងយេរូសាឡិម និងនៅទីក្រុងរ៉ូមទៀត។ ព្រះជាម្ចាស់មានបន្ទូលទៅកាន់សាវ័កប៉ុលថា លោកចាំបាច់ត្រូវចុះទៅទីក្រុងទាំងពីរនេះ។

យើងគួរកត់សម្គាល់ថា ព្រះជាម្ចាស់មិនបានបន្ទោសដល់សាវ័កប៉ុលដោយសារលោកចុះទៅទីក្រុងយេរូសាឡិមទេ។ ផ្ទុយទៅវិញ ទ្រង់លើកទឹកចិត្តដល់លោកយ៉ាងកក់ក្តៅ។ ព្រះជាម្ចាស់មានផែនការ ដើម្បីប្រើសាវ័កប៉ុលអោយទៅធ្វើទីបន្ទាល់នៅទីក្រុងរ៉ូម។

## ផែនការសម្ងាត់ក្នុងការសម្លាប់សាវ័កប៉ុល

**ដល់ភ្លឺឡើង មានពួកសាសន៍យូដាខ្លះ រួមគំនិតគ្នាស្បថឡាក់ឡាំងថា មិនស៊ីមិនផឹកទាល់តែបានសំឡាប់ប៉ុលហើយ (កិច្ចការ ២៣:១២)។**

មានមនុស្សដែលមិនឃ្លានបាយ មិនឃ្លានទឹក បើមិនបានសម្លាប់លោកប៉ុលទេ។ ក្នុងលោកយើងនេះ ពិតជាមានមនុស្សពាលយ៉ាងដូច្នោះមែន។

**[១៣]ឯមនុស្សដែលបង្កើតឧបាយយ៉ាងនេះ មានជាង៤០នាក់ [១៤]គេក៏ទៅជំរាបពួកសង្គ្រាជ នឹងពួកចាស់ទុំថា យើងខ្ញុំបានស្បថថា មិនភ្លក់អ្វីសោះ ទាល់តែបានសំឡាប់ប៉ុលចេញ [១៥]ដូច្នេះ សូមឱ្យលោកទាំងឡាយ នឹងពួកក្រុមជំនុំ ចាត់ឱ្យទៅសូមវាពីលោកមេទ័ពធំមកឥឡូវ ដើម្បីឱ្យលោកនាំវាចុះមក ធ្វើដូចជាលោកចង់ពិចារណាសួរ ពីដំណើរវា ឱ្យច្បាស់លាស់ឡើង ឯពួកយើងខ្ញុំក៏ប្រុងប្រៀបជាស្រេចនឹងសំឡាប់វា មុនដែលវាចូលមកដល់ផង (កិច្ចការ២៣:១៣-១៥)។**

សេចក្ដីខាងលើ បញ្ជាក់ពីឧបាយកលដែលគេធ្វើឡើង ដើម្បីសម្លាប់សាវ័កប៉ុលដោយសម្ងាត់។ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់មានបន្ទូលមកកាន់សាវ័កប៉ុលយ៉ាងច្បាស់ថា ទ្រង់មានផែនការផ្សេងពីពួកដែលធ្វើឧបាយកលលបសម្លាប់លោក។ ឯផែនការរបស់ព្រះជាម្ចាស់នោះ គឺសាវ័កប៉ុលត្រូវធ្វើដំណើរទៅធ្វើទីបន្ទាល់ពីព្រះនាមទ្រង់នៅទីក្រុងរ៉ូម។

**[១៦]ឯកូនរបស់ប្អូនស្រីប៉ុល កាលបានដឹងពីការដែលឈ្លបលបនោះហើយ ក៏ចូលទៅក្នុងបន្ទាយប្រាប់ដល់ប៉ុល [១៧]នោះប៉ុល គាត់ហៅមេទ័ពរងម្នាក់មកជំរាបថា សូមនាំអ្នកកំឡោះនេះទៅឯលោកមេ**

**ទំពធំទៅ ដ្បិតវាមានរឿងខ្លះចង់ជំរាបលោក [១៨]អ្នកនោះក៏នាំវា
ទៅឯលោកមេទ័ពធំជំរាបថា ប៉ុល ជាអ្នកទោសបានហៅខ្ញុំ
ហើយសូមខ្ញុំឱ្យនាំអ្នកកំឡោះនេះមកឯលោក វាមានរឿងខ្លះចង់
ជំរាបដល់លោក (កិច្ចការ២៣:១៦-១៨)។**

សាវ័កប៉ុលប្រើសិទ្ធិ ក្នុងនាមលោកមានសញ្ជាតិរ៉ូម។ លោកមានសិទ្ធិគ្រប់គ្រាន់ ដើម្បីការពារខ្លួន។ ម្យ៉ាងវិញទៀតយើងដឹងថា សាវ័កប៉ុលមានបងប្អូនដែរ។ លោកមានប្អូនស្រីដែលរស់នៅជាមួយសាច់ញាតិរបស់លោកនៅទីក្រុងយេរូសាឡិម។

**[១៩]មេទ័ពធំក៏ចាប់ដៃវា នាំទៅដោយឡែក សួរថា ឯងមានរឿងអ្វី
នឹងប្រាប់ដល់អញខ្លះ [២០]វាជំរាបថា ពួកសាសន៍យូដាបានស្រុះចិត្ត
គ្នានឹងសូមលោក ឱ្យនាំប៉ុលចុះទៅឯពួកក្រុមជំនុំ នៅវេលាថ្ងៃ
ស្អែក ធ្វើដូចជាចង់ពិចារណាសួរពីដំណើរគាត់ ឱ្យច្បាស់ឡើង
[២១]ដូច្នេះ សូមលោកកុំព្រមតាមគេឡើយ ដ្បិតមានពួកគេចំនួន
ជាង៤០នាក់ បានលបចាំគាត់តាមផ្លូវ គេបានស្បថថា មិនស៊ី
មិនផឹកអ្វីឡើយ ទាល់តែបានសំឡាប់គាត់ចេញ ឥឡូវនេះ គេ
ប្រុងប្រៀបជាស្រេចហើយ ចាំតែលោកអនុញ្ញាតឱ្យប៉ុណ្ណោះទេ
[២២]នោះមេទ័ពធំឱ្យអ្នកកំឡោះនោះទៅវិញ ទាំងហាមមិនឱ្យប្រាប់**

**ដល់អ្នកណា ពីដំណើរដែលវាជំរាបលោកនោះឡើយ (កិច្ចការ ២៣:១៩-២២)។**

ក្មួយរបស់សាវ័កប៉ុលបាននាំរឿងសម្ងាត់ទៅប្រាប់មេទ័ព។ ដូច្នេះ មេទ័ពក៏ដឹងពីឧបាយកលដែលគេធ្វើដោយសម្ងាត់ ដើម្បីសម្លាប់សាវ័កប៉ុល។ ខ្ញុំចង់ផ្អាកមេរៀនបន្តិចត្រង់នេះ ហើយបែរមកនិយាយអំពីព្រះហឫទ័យបំណងរបស់ព្រះចំពោះគ្រីស្ទបរិស័ទដែលមានរោគាអ្វីមួយប្រចាំកាយ។ អ្នកខ្លះនិយាយថា បើគ្រីស្ទបរិស័ទមានរោគាអ្វីមួយប្រចាំកាយ គេមិនចាំបាច់ទៅរកគ្រូពេទ្យដើម្បីព្យាបាលទេ គឺត្រូវអធិស្ឋានដល់ព្រះជាម្ចាស់។ បើព្រះអង្គអោយជា នោះបានជាហើយ បើមិនជា នោះក៏តាមតែព្រះទ័យបំណងរបស់ព្រះអង្គទៅចុះ។ ខ្ញុំយល់ថា ជំនឿបែបនេះជាការប្រកាន់គោលទិស្ដាំនិយមហួសហេតុពេកហើយ។ មែនហើយ! គ្រីស្ទបរិស័ទដែលមានរោគាអ្វីមួយ ពិតជាជឿដល់ព្រះជាម្ចាស់ ព្រមទាំងផ្ទេររោគារបស់ខ្លួនថ្វាយដល់ព្រះអង្គ។ ទ្រង់ជាគ្រូពេទ្យលើអស់ទាំងគ្រូពេទ្យ។ ប៉ុន្តែគ្រីស្ទបរិស័ទប្រភេទនោះ ត្រូវជឿថា ព្រះជាម្ចាស់បង្កើតអោយមនុស្សចេះធ្វើជាគ្រូពេទ្យដែរ។ នៅក្នុងករណីសាវ័កប៉ុល លោកជឿថា ព្រះជាម្ចាស់អាចរំដោះលោកអោយរួចពីស្ថានភាពនេះបាន ដ្បិតព្រះជាម្ចាស់ទើបនឹងយាងមកមានបន្ទូលមកកាន់លោកថា លោកត្រូវទៅទីក្រុងរ៉ូម។ បើផែនការសម្ងាតអាចសម្លាប់សាវ័កប៉ុលបាន លោកច្បាស់ជាមិនបានទៅទីក្រុងរ៉ូម ដូចព្រះជាម្ចាស់បង្គាប់លោកទេ។ ប៉ុន្តែ ទោះជាលោកជឿដល់ព្រះជាម្ចាស់ថា ព្រះអង្គអាចនឹងរំដោះលោកបានក៏ដោយ

លោកត្រូវប្រើមធ្យោបាយ គឺបញ្ជូនក្មួយរបស់លោកអោយទៅជម្រាបដំណឹងនេះ ដល់មេទ័ពរាជការរ៉ូម។ សាវ័កប៉ុលប្រើមធ្យោបាយដើម្បីអោយសម្រេចតាមទិសដៅ ដែលព្រះជាម្ចាស់មានសម្រាប់រូបលោក។ យើងក៏ដូចគ្នាដែរ បើយើងឈឺត្រូវរកគ្រូពេទ្យ ដ្បិតគ្រូពេទ្យនោះ ជាមធ្យោបាយដែលព្រះជាម្ចាស់ផ្តល់មកសម្រាប់ព្យាបាលរោគាយើង។

## គេបញ្ជូនសាវ័កប៉ុលទៅក្រុងសេសារា

ក្រោយពីពេលដែលដឹងថា មានគេធ្វើឧបាយកលសម្ងាត់ ដើម្បីសម្លាប់សាវ័កប៉ុល លោកមេទ័ពបញ្ជាអោយត្រៀមកងទ័ពមួយកងធំ ប្រដាប់ដោយអាវុធគ្រប់ដៃ និងសេះចម្បាំង ដើម្បីទៅរំដោះលោក។

**លោកក៏ហៅមេទ័ពរង២នាក់មកប្រាប់ថា ចូររៀបទាហានថ្មើរជើង២០០នាក់ ពលសេះ៧០ និងពលកាន់លំពែង២០០ ឱ្យទាន់ក្នុងវេលាម៉ោង៩យប់នេះ ដើម្បីនឹងទៅឯសេសារា (កិច្ចការ ២៣:២៣)។**

លោកមេទ័ពរូបនេះ មានទាហានរាប់រយនាក់ ដែលស្ថិតនៅក្រោមបញ្ជារបស់លោក។

**ហើយឱ្យមានជំនិះសំរាប់ប៉ុលជិះដែរ ដើម្បីនឹងនាំទៅឯលោកភេលីច ជាចៅហ្វាយខេត្តដោយសុខសាន្ត (កិច្ចការ២៣:២៤)។**

ទាហានមួយកងប្រដាប់ដោយអាវុធ និងសេះចម្បាំង បានចុះទៅទីក្រុងសេសារា ដើម្បីរំដោះសាវ័កប៉ុល។ កិរិយានេះ គឺជាកិរិយាដែលរាប់ថាជំនឿទុកចិត្តលើព្រះជាម្ចាស់របស់សាវ័កប៉ុល។ លោកជឿដល់ព្រះជាម្ចាស់ថា ទ្រង់នឹងយាងមករំដោះលោក។ ឯការរំដោះនោះទៀតសោត គឺលោកត្រូវប្រើសិទ្ធិរបស់លោក ក្នុងនាមលោកជាសញ្ជាតិរ៉ូម។ សាវ័កប៉ុលបានធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះ បានជាលោកបញ្ជូនក្មួយរបស់លោកអោយទៅប្រាប់លោកមេទ័ពសាសន៍រ៉ូម។ ចំណែកឯសាសន៍យូដាវិញ គេដេកមិនលក់បក់មិនល្ហើយ ពីព្រោះគេមិនបានសម្លាប់សាវ័កប៉ុល ដូចឧបាយកលដែលគេបានគ្រោងទុក។

លោកមេទ័ពបានបញ្ជូនសាវ័កប៉ុលទៅក្រុងសេសារា ដើម្បីបំភ្លឺរឿងក្តីនោះដល់លោកភេលីច ដែលត្រូវជាចៅហ្វាយខេត្តគ្រប់គ្រងខេត្តយូដាទាំងមូល។ ក្រុងសេសារាជារមណីយដ្ឋានរបស់ឥស្សរជនជាន់ខ្ពស់នៃរាជការរ៉ូម។ លោកពីឡាត់ក៏មានផ្ទះនៅក្នុងរមណីយដ្ឋាននោះដែរ។

គេបញ្ជូនសាវ៉កប៉ុលទៅអោយចៅហ្វាយខេត្តភេលីច បន្ទាប់ពីគេបានរំដោះលោកចេញពីទីក្រុងយេរូសាឡិមអោយផុតពីគ្រោះថ្នាក់។

**លោកក៏ធ្វើសំបុត្រ១ច្បាប់ មានសេចក្តីបែបដូច្នេះថា (កិច្ចការ ២៣:២៥)។**

ត្រង់នេះ បណ្ឌិតលូកាប្រហែលជាមានសំបុត្ររបស់មេទ័ពសរសេរទៅកាន់លោកចៅហ្វាយខេត្តផង បានជាលោកសរសេរ "...មានសេចក្តីបែបដូច្នេះថា"។ ប៉ុន្តែយើងអាចសន្និដ្ឋានបានថា លោកប្រហែលជាមិនមានសំបុត្រនោះទេ គ្រាន់តែលោកយល់ថា សេចក្តីនៅក្នុងសំបុត្រនោះមានខ្លឹមសារយ៉ាងនេះមួយ។

**សំបុត្រក្លូឌាស-លូស៊ា សូមក្រាបប្រណិប័តន៍ ចូលមកដល់លោកចៅហ្វាយភេលីច ដ៏ជាធំ សូមទានជ្រាប (កិច្ចការ២៣:២៦)។**

នៅសម័យដើម គេមិនចុះហត្ថលេខានៅលើសំបុត្រដូចយើងសព្វថ្ងៃនេះឡើយ។ អ្នកដែលសរសេរសំបុត្រត្រូវសរសេរឈ្មោះរបស់ខ្លួន នៅពេលចាប់ផ្តើមសរសេរសំបុត្រទៅកាន់នរណាម្នាក់។

**មនុស្សនេះ ពួកសាសន៍យូដាបានចាប់ ហើយគេរៀបនឹងសំឡាប់បង់ ប៉ុន្តែខ្ញុំនាំទាហានទៅទាន់ដោះរួចពីពួកគេចេញ ដោយបានឮថាជាសាសន៍រ៉ូមដូច្នេះ (កិច្ចការ២៣:២៧)។**

លោកមេទ័ពដែលទទួលការខុសត្រូវរក្សាសន្តិសុខ នៅទីក្រុងយេរូសាឡិមចង់អោយចៅហ្វាយខេត្ត ដែលស្ថិតនៅទីក្រុងសេសារាដឹងថា លោកបានបំពេញនាទីរបស់លោក គឺលោកត្រូវការពារសិទ្ធិអ្នកមានសញ្ជាតិរ៉ូម។

**២៨ ហើយដែលខ្ញុំចង់ដឹង ពីហេតុអ្វីបានជាគេចោទប្រកាន់វា នោះខ្ញុំបាននាំចុះទៅនៅមុខពួកក្រុមជំនុំរបស់គេ ២៩ ក៏ឃើញថា គេចោទប្រកាន់ពីរឿងជជែកគ្នា ខាងឯក្រិត្យវិន័យរបស់គេទេ តែគ្មានហេតុអ្វីដែលគួរឱ្យស្លាប់ ឬជាប់ចំណងសោះឡើយ (កិច្ចការ ២៣:២៨-២៩)។**

លោកក្លូឌាស-លូស៊ា ពិតជាមិនដឹងអំពីមូលហេតុអ្វីដែលគេខឹងសម្បារជាមួយនឹងសាវ័កប៉ុលមែន។ បើតាមលោកយល់ លោកគ្រាន់តែគិតថា ពួកសាសន៍យូដាហើយនិងសាវ័កប៉ុលមានការមិនចុះសម្រុងគ្នា ស្តីអំពីច្បាប់ទម្លាប់ខាងសាសនា។ បើតាមច្បាប់របស់រាជការរ៉ូម សាវ័កប៉ុលមិនមានកំហុសអ្វីដែលគួរអោយគេយកមកចង ឬ

ក៏យកទៅសម្លាប់ឡើយ។

[៣០]កាលមានគេមកប្រាប់ខ្ញុំពីឧបាយកល ដែលពួកសាសន៍យូដាគិត
ធ្វើដល់វា នោះខ្ញុំក៏បញ្ជូនមកឯលោកភ្លាម ទាំងប្រាប់ពួកអ្នកដើម
ចោទ ឱ្យគេមកចោទប្រកាន់នៅចំពោះលោកចុះ សូមឱ្យលោក
បានប្រកបដោយសេចក្ដីសុខសាន្ត សេចក្ដីគួរពុំគួរ សូមទានអភ័យ
ទោស [៣១]ដូច្នេះ ពួកពលក៏នាំយកប៉ុលទាំងយប់ ទៅឯក្រុង
អាន់ទីប៉ាទ្រីស តាមបង្គាប់ [៣២]ស្អែកឡើង គេទុកពលសេះឱ្យទៅ
ជាមួយនឹងគាត់ រួចគេត្រឡប់មកឯបន្ទាយវិញ [៣៣]កាលចូលក្រុង
សេសារា ហើយជូនសំបុត្រដល់លោកចៅហ្វាយ នោះក៏ប្រគល់
ប៉ុលទៅលោកដែរ [៣៤]កាលលោកបានមើលសំបុត្ររួចជាស្រេច
ហើយ នោះលោកសួរពីគាត់នៅខេត្តណា លុះជ្រាបថា នៅស្រុក
គីលីគា [៣៥]ក៏មានប្រសាសន៍ថា ចាំកាលណាពួកដើមចោទបានចុះ
មកដល់ នោះអញនឹងស្ដាប់រឿងឯងសព្វគ្រប់ រួចលោកបង្គាប់ឱ្យ
ឃុំគាត់ ទុកក្នុងសាលាជំនុំរបស់ស្ដេចហេរ៉ូឌ (កិច្ចការ២៣:
៣០-៣៥)។

ពួកអ្នកដើមចោទធ្វើដំណើរតាមសាវ័កប៉ុល ដូចស្រមោលអន្ទោលតាមប្រាណ។ នៅពេលដែលគេយកសាវ័កប៉ុលមកអោយបំភ្លឺរឿងក្តី លោកមិនដោះសាពីរឿងផ្ទាល់ខ្លួនឡើយ គឺលោកឆ្លៀតឱកាសនេះ ដើម្បីផ្សព្វផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអម្ចាស់យេស៊ូវបង្គាប់ដល់សាវ័កប៉ុលថា លោកត្រូវធ្វើទីបន្ទាល់នៅមុខចៅហ្វាយខេត្ត នៅមុខមន្ត្រី និងនៅមុខក្សត្រនានាផង។ ដោយសារមូលហេតុនេះហើយ បានជាគេយកលោកអោយឈរនៅមុខទីកាត់ទោស។ ព្រះជាម្ចាស់ប្រើមធ្យោបាយបែបនេះ ដើម្បីអោយព្រះបន្ទូលរបស់ព្រះអង្គបានឮដល់ពួកនាហ្មឺន មន្ត្រីគ្រប់ជាន់ថ្នាក់។ សាវ័កប៉ុលធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឯព្រះជាម្ចាស់វិញប្រើសាវ័កប៉ុលដើម្បីសម្រេចទិសដៅរបស់ទ្រង់។

យើងស្វែងការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តមដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"